ទម្រង់ទី៣៣

| សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ<br>សម្រាប់កិច្ចសន្យាការងារសាងសង់របស់ក្រុមប្រឹក្សាឃុំ | | |
|---|---|---|
| ខេត្តៈ កំពង់ធំ | ស្រុកៈ ប្រាសាទសំបូរ | ឃុំ ៖ ឈូក |

ការពិពណ៌នាអំពីលទ្ធផលកិច្ចសន្យា ៖
ការសាងសង់ ៖ ជួសជុលទំនប់ស្ទាក់ទឹកតាំងសៀន ប្រវែង២២៥ម៉ែត្រ ទទឹងខ្នងលើ៥ម៉ែត្រ និងសាងសង់លូប្រអប់ទ្វាទឹកឈើ ភ្លោះមុខកាត់២,៥ម៉ែត្រ x កំពស់២ម៉ែត្រ និងប្រវែង៦ម៉ែត្រ ១កន្លែង។
រយៈពេលថែទាំ ៖ ៦ខែ

| | |
|---|---|
| តម្លៃប៉ាន់ស្មាន | ១៦.៧៤៤,៧១ ដុល្លារ<br>( ដប់ប្រាំមួយពាន់ប្រាំពីររយសែសិបបួនដុល្លារនិងចិតសិបមួយ ) |
| អ្នកដែលអាចដេញថ្លៃ | អ្នកទទួលការប្រភេទ ១ និង២ |
| ប្រាក់កក់ធានាការដេញថ្លៃ | ៣៣៥ ដុល្លារ |
| ឈ្មោះធនាគារពាណិជ្ជដែលត្រូវតម្កល់ប្រាក់កក់ | ធនាគារពាណិជ្ជណាមួយ |
| រយៈពេលសុពលភាពនៃសំណើដេញថ្លៃ | ចំនួន៤៥ ( សែសិបប្រាំ ) ថ្ងៃ ចាប់ពីថ្ងៃប្រជុំបើកសំណើដេញថ្លៃ |
| ទីកន្លែងដែលអាចទទួលឯកសារដេញថ្លៃ | សាលាឃុំឈូក ឬគេហទំព័រដេញថ្លៃរបស់ គ.ជ.អ.ប និង គ.ជ.គ.ម |
| ទីកន្លែងនៃការប្រជុំបើកសំណើដេញថ្លៃ | សាលាឃុំឈូក |
| កាលបរិច្ឆេទនៃការប្រជុំបើកសំណើដេញថ្លៃ | ថ្ងៃទី.24... ខែ តុលា ឆ្នាំ២០១៧ |
| • ពេលវេលាចាប់ផ្តើមទទួលសំណើដេញថ្លៃ | ម៉ោង ០៩:០០ នាទី |
| • ពេលវេលាឈប់ទទួលសំណើដេញថ្លៃ | ម៉ោង ០៩:១០ នាទី |
| • ពេលវេលាបើកសំណើដេញថ្លៃ | ម៉ោង ០៩:១០ នាទី |

**កំណត់សម្គាល់៖**

- អ្នកដេញថ្លៃឈ្នះក្នុងការដេញថ្លៃនឹងត្រូវតម្កល់ប្រាក់កក់ធានាការអនុវត្តចំនួន១០%នៃតម្លៃកិច្ចសន្យា។ ប្រាក់កក់នេះមានសុពលភាពរហូតដល់ចប់រយៈពេលថែទាំលទ្ធផលកិច្ចសន្យា ឬរយៈពេលធានាគុណភាពសំណង់ ( ទម្រង់ប្រាក់កក់ធានាការអនុវត្តមានភ្ជាប់ជូនក្នុងឯកសារដេញថ្លៃ )។
- អ្នកទទួលការត្រូវទទួលខុសត្រូវទាំងស្រុងក្នុងការថែទាំលទ្ធផលកិច្ចសន្យា និងជួសជុលនូវរាល់ការខូចខាតទាំងអស់នៅក្នុងអំឡុងពេល ៦ខែ បន្ទាប់ពីសាងសង់រួចជាស្ថាពរ។
- អ្នកទទួលការត្រូវចូលរួមដេញថ្លៃប្រកបដោយការប្រកួតប្រជែង ដោយគ្មានឃុបឃិតស៊ុមគ្រលំគ្នា និងមិនពាក់ព័ន្ធនឹងការក្លែងបន្លំ ឬអំពើពុករលួយ។ ប្រសិនបើអ្នកទទួលការណាឃុបឃិតស៊ុមគ្រលំគ្នា ឬពាក់ព័ន្ធក្នុងការក្លែងបន្លំ ឬអំពើពុករលួយជាមួយអ្នកទទួលការដទៃ អ្នកទទួលការទាំងនោះនឹងត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកទទួលការជារៀងរហូត និងមិនត្រូវបានអនុញ្ញាតឱ្យដាក់សំណើដេញថ្លៃគម្រោងឃុំទាំងអស់នៅទូទាំងប្រទេសកម្ពុជា ហើយប្រាក់កក់ធានាការដេញថ្លៃរបស់អ្នកដេញថ្លៃទាំងនោះនឹងត្រូវបានរឹបអូសផ្ទេរបង្វែរបង់ចូលថវិការដ្ឋ។
- អាសយដ្ឋានដើម្បីសាកសួរព័ត៌មាន និងទទួលយកឯកសារដេញថ្លៃគឺ លោក...ហ៊ីណា ចេង.......
លេខទូរសព្ទ: 0975246283

ថ្ងៃទី.04.....ខែ តុលា ឆ្នាំ២០១៧
**មេឃុំ**

ជួន_ជីង

ទម្រង់ទី៣៦

# សំណើដេញថ្លៃ
## សម្រាប់កិច្ចសន្យាការងារសាងសង់របស់ក្រុមប្រឹក្សាឃុំ

| ខេត្ត៖ កំពង់ធំ | ស្រុក៖ ប្រាសាទសំបូរ | ឃុំ៖ ឈូក |
|---|---|---|
| ឈ្មោះគម្រោង ៖ ជួសជុលទំនប់ស្ទាក់ទឹកតាំងសៀន | | |
| ឈ្មោះអ្នកដេញថ្លៃ ៖ ........................................ | ឈ្មោះក្រុមហ៊ុន ៖ ........................................ | លេខអត្តសញ្ញាណប័ណ្ណ ៖ ........................................ |

| ល.រ | ការពិពណ៌នា | ភូមិ | បរិមាណ | ឯកតា | តម្លៃឯកតា | តម្លៃសរុប (ដុល្លារ) |
|---|---|---|---|---|---|---|
| ១ | ជួសជុលទំនប់ស្ទាក់ទឹកតាំងសៀន ប្រវែង០,២២៥គ.ម ទទឹងខ្នងលើ៥ម៉ែត្រ។ | ស្មៀ | ០,២២៥ | គ.ម | | |
| ៣ | សាងសង់លូប្រអប់ទ្វាទឹកឈើភ្លោះមុខកាត់២,៥ម៉ែត្រ x កំពស់២ម៉ែត្រ និងប្រវែង ៦ម៉ែត្រ ១កន្លែង។ | ស្មៀ | ១ | កន្លែង | | |
| | សរុបតម្លៃដាក់ដេញ | | | | | |

(តម្លៃដាក់ដេញសរុបជាអក្សរ..........................................................................................................................
.......................................................................................................................................................)។

- អ្នកដេញថ្លៃឈ្នះក្នុងការដេញថ្លៃនឹងត្រូវតែមល់ប្រាក់កក់ធានាការអនុវត្តចំនួន១០%នៃតម្លៃកិច្ចសន្យា។ ប្រាក់កក់នេះមានសុពលភាពរហូតដល់ចប់រយៈពេលថែទាំលទ្ធផលកិច្ចសន្យា ឬរយៈពេលធានាគុណភាពសំណង់។
- ខ្ញុំជាអ្នកដេញថ្លៃបានអាន និងយល់ច្បាស់អំពីកិច្ចសន្យា គំនូសប្លង់ និងសេចក្តីលម្អិតបច្ចេកទេស។ ខ្ញុំបានយល់ព្រមសាងសង់ទៅតាមកិច្ចសន្យា ពេលវេលាដែលបានកំណត់ និងជួសជុលថែទាំលទ្ធផលកិច្ចសន្យាឱ្យស្ថិតនៅក្នុងល័ក្ខខណ្ឌល្អក្នុងរយៈពេល៦ខែបន្ទាប់ពីសាងសង់រួចជាស្ថាពរ។
- អ្នកទទួលការត្រូវចូលរួមដេញថ្លៃប្រកបដោយការប្រកួតប្រជែង ដោយគ្មានឃុបឃិតស៊ុមគ្រលំគ្នា និងមិនពាក់ព័ន្ធនឹងការក្លែងបន្លំ ឬអំពើពុករលួយ។ ប្រសិនបើអ្នកទទួលការណាឃុបឃិតស៊ុមគ្រលំគ្នា ឬពាក់ព័ន្ធក្នុងការក្លែងបន្លំ ឬអំពើពុករលួយជាមួយអ្នកទទួលការដទៃ អ្នកទទួលការទាំងនោះនឹងត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកទទួលការជារៀងរហូត និងមិនត្រូវបានអនុញ្ញាតឱ្យដាក់សំណើដេញថ្លៃគម្រោងឃុំទាំងអស់នៅទូទាំងប្រទេសកម្ពុជា ហើយប្រាក់កក់ធានាការដេញថ្លៃរបស់អ្នកដេញថ្លៃទាំងនោះនឹងត្រូវបានរឹបអូសផ្ទេរបង្វែរបង់ចូលថវិការដ្ឋ។
- កំហុសមួយចំនួនអាចត្រូវបានកែតម្រូវដោយគណៈកម្មការលទ្ធកម្ម។ ប្រសិនបើអ្នកដេញថ្លៃមិនទទួលយកការកែតម្រូវនេះទេ គណៈកម្មការលទ្ធកម្មនឹងបដិសេធសំណើដេញថ្លៃនេះ ដោយចាត់ទុកថា ជាសំណើដេញថ្លៃដែលមិនមានសុពលភាព។

កំណត់សម្គាល់៖សំណើដេញថ្លៃនេះមានសុពលភាពរយៈពេល៤៥ថ្ងៃចាប់ពីកាលបរិច្ឆេទនៃការប្រជុំបើកសំណើដេញថ្លៃ។

ថ្ងៃទី............. ខែ............... ឆ្នាំ២០១៧

**ហត្ថលេខា និងឈ្មោះអ្នកដេញថ្លៃ**

ទម្រង់ទី៣៩

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីប្រកាសស្តីពី
# ក្រមសីលធម៌ ការមិនក្លែងបន្លំ និងការមិនប្រព្រឹត្តិអំពើពុករលួយ

ខ្ញុំជាអ្នកទទួលការសាងសង់ អ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ទំនិញសូមប្រកាសអះអាងដូចខាងក្រោមៈ

១. ខ្ញុំ បុគ្គលិករបស់ខ្ញុំ ទីប្រឹក្សារបស់ខ្ញុំ អ្នកសហការ/ដៃគូរបស់ខ្ញុំ ភ្នាក់ងាររបស់ខ្ញុំ ម្ចាស់ភាគហ៊ុនរបស់ខ្ញុំ និងសាច់ញាតិរបស់ខ្ញុំព្រមទាំងអ្នកសហការ និងសាច់ញាតិរបស់ពួកគេ នឹងមិនមានទំនាក់ទំនងណាមួយដែលជាទំនាស់ផលប្រយោជន៍ដែលបានចែងនៅក្នុងឯកសារដេញថ្លៃ។

២. បើយើងខ្ញុំបានដឹងអំពីទំនាស់ផលប្រយោជន៍ទាំងនេះ យើងខ្ញុំនឹងរាយការណ៍ភ្លាមជូនទៅគណៈកម្មការលទ្ធកម្ម ឃុំ អភិបាលខេត្ត ក្រុង និងក្រុមការងារគណនេយ្យភាពខេត្ត ក្រុង។

៣. ខ្ញុំ បុគ្គលិករបស់ខ្ញុំ ទីប្រឹក្សារបស់ខ្ញុំ អ្នកសហការ/ដៃគូរបស់ខ្ញុំ ភ្នាក់ងាររបស់ខ្ញុំ ម្ចាស់ភាគហ៊ុនរបស់ខ្ញុំ និងសាច់ញាតិរបស់ខ្ញុំ ព្រមទាំងអ្នកសហការ និងសាច់ញាតិរបស់ពួកគេ នឹងមិនប្រព្រឹត្តអំពើពុករលួយ ក្លែងបន្លំ បង្ខាប់បញ្ជា និងឃុបឃិតស៊ីគ្រលំចំពោះការដាក់សំណើដេញថ្លៃរបស់ខ្ញុំឡើយ។

៤. យើងខ្ញុំបានដឹងច្បាស់អំពីកាតព្វកិច្ចរបស់ខ្លួន ដែលត្រូវអនុញ្ញាតឱ្យរដ្ឋាភិបាល និងឬទីភ្នាក់ងារផ្តល់មូលនិធិធ្វើការ ត្រួតពិនិត្យនូវរាល់ឯកសារនានាដែលទាក់ទងនឹងការរៀបចំសំណើដេញថ្លៃរបស់យើងខ្ញុំ និងកិច្ចសន្យាណាមួយដែល អាចជាលទ្ធផលពីភាពមិនប្រក្រតីដែលគិតស្មានមិនដល់ ទោះបីជាកិច្ចសន្យានោះយើងខ្ញុំឈ្នះ ឬចាញ់ក៏ដោយ។

៥. នៅក្នុងដំណើរការនៃការអនុវត្តកិច្ចលទ្ធកម្ម និងកិច្ចសន្យាណាមួយដែលឈ្នះក្នុងការដេញថ្លៃនេះ ខ្ញុំ បុគ្គលិករបស់ខ្ញុំ ទីប្រឹក្សារបស់ខ្ញុំ អ្នកសហការ/ដៃគូរបស់ខ្ញុំ ភ្នាក់ងាររបស់ខ្ញុំ ម្ចាស់ភាគហ៊ុនរបស់ខ្ញុំ និងសាច់ញាតិរបស់ខ្ញុំ ព្រម ទាំងអ្នកសហការ និងសាច់ញាតិរបស់ពួកគេ នឹងមិនមានចំណាយប្រាក់ ឬផ្តល់ជូនជាសារគុណឱ្យទៅបុគ្គលិក ទីប្រឹក្សា អ្នកសហការ ឬសាច់ញាតិនៃអ្នកដែលពាក់ព័ន្ធនៅក្នុងដំណើរការលទ្ធកម្ម ការអនុវត្តគម្រោង និង ការចេញ មូលប្បទានប័ត្រទូទាត់។

ក្នុងករណីមិនគោរពតាមខ្លឹមសារនៃសេចក្តីប្រកាសនេះ ខ្ញុំជាអ្នកទទួលការ អ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ទំនិញ នឹងមិនត្រូវបានអនុញ្ញាតឱ្យដាក់សំណើដេញថ្លៃគម្រោងឃុំទាំងអស់នៅទូទាំងប្រទេសកម្ពុជា ហើយប្រាក់កក់ធានាការដេញថ្លៃរបស់អ្នកដេញថ្លៃទាំងនោះនឹងត្រូវបានរឹបអូសផ្ទេរបង្វែរបង់ចូលថវិការដ្ឋ។

ថ្ងៃទី..............ខែ..............ឆ្នាំ២០១៧

**ហត្ថលេខា និងឈ្មោះអ្នកដេញថ្លៃ**

# ការប៉ាន់ស្មានតម្លៃលម្អិតសម្រាប់លទ្ធផលការងារដី

| ខេត្តៈ កំពង់ធំ | | ស្រុកៈ ប្រាសាទសំបូរ | | ឃុំៈ ឈូក | |
|---|---|---|---|---|---|
| ឈ្មោះគម្រោងៈ ជួសជុលទំនប់ស្នាក់ទឹកតាំងសៀន | | | | លេខកូដឃុំ | ៦០៥០១ |
| ភូមិៈ ស្អៀ | | **លទ្ធផលគម្រោងៈ**ជួសជុលទំនប់ស្នាក់ទឹកតាំងសៀនប្រវែង ២២៥ម៉ែត្រ ទទឹងខ្នងលើ ៥ម៉ែត្រ | | | លេខកូដលទ្ធផល<br>1020301 |
| **ល.រ** | **ការពិពណ៌នា** | **ឯកតា** | **ចំនួន** | **តម្លៃឯកតា** ($) | **សរុប** ($) |
| ១ | ឈូសឈាយសំអាតទីតាំង | ម$^{២}$ | 680.69 | | |
| ២ | ទិញដី | ម$^{៣}$ | 3,332.65 | | |
| ៣ | ការងារជីកដី | ម$^{៣}$ | 3,332.65 | | |
| ៤ | ការងារជីកជញ្ជូនដី ១ គម | ម$^{៣}$ | 3,332.65 | | |
| ៥ | កៀរស្រោចទឹកបង្ហាប់ដី | ម$^{៣}$ | 3,332.65 | | |
| ៦ | ការងារដាំស្មៅ | ម$^{២}$ | 1,931.15 | | |
| ៧ | ដឹកជញ្ជូនសំភារៈចូលការដ្ឋាន | តោន | 20.00 | | |
| ៨ | ដឹកជញ្ជូនសំភារៈចេញពីការដ្ឋាន | តោន | 20.00 | | |
| ៩ | ស្លាកសញ្ញាគម្រោង | កន្លែង | 1.00 | | |
| សរុបតម្លៃ | | | | | |

យើងខ្ញុំយល់ព្រមនូវ តម្លៃឯកតាខាងលើនឹងប្រើសម្រាប់ការគណនាតម្លៃការងារបន្ថែម ដែលបានណែនាំ និង យល់ព្រមដោយអ្នកគ្រប់គ្រងគម្រោង ។

ហត្ថលេខា និងត្រា

ឈ្មោះ ........................................................

មុខងារ ........................................................

កាលបរិច្ឆេទ..................................................

# ការប៉ាន់ស្មានតម្លៃលម្អិតសម្រាប់លទ្ធផលការងារសំណង់លូប្រអប់ភ្លោះទ្វារឈើ

| ខេត្តៈ កំពង់ធំ | ស្រុកៈ ប្រាសាទសំបូរ | ឃុំៈ ឈូក |
|---|---|---|
| ឈ្មោះគម្រោងៈជួសជុលទំនប់ស្ពាក់ទឹកតាំងសៀន | | លេខកូដឃុំៈ ៦០៥០១ |
| ភូមិៈ ស្មៀ | លទ្ធផលគម្រោងៈ សាងសង់លូប្រអប់ទ្វាទឹកឈើភ្លោះមុខកាត់២,៥ ម៉ែត្រ x កំពស់២ម៉ែត្រ និងប្រវែង៦ម៉ែត្រ ១កន្លែង។ | |

**ការប៉ាន់ស្មានតម្លៃសម្រាប់លទ្ធផលនាំងមូល**

| លរ | ការពិពណ៌នា | ឯកតា | ចំនួន | តម្លៃឯកតា($) | សរុប ($) |
|---|---|---|---|---|---|
| ១ | ស៊ីម៉ង់ត៍ | បាវ | 279.00 | | |
| ២ | ខ្សាច់ | ម³ | 22.00 | | |
| ៣ | ដែកសរសៃ | គក្រ | 1,515.00 | | |
| ៤ | ថ្ម ១០x២០ | ម³ | 39.50 | | |
| ៥ | ថ្ម ៤០x៦០ | ម³ | 4.00 | | |
| ៦ | ថ្មទំហំ ២០០មម | ម³ | 6.20 | | |
| ៧ | ឈើលេខ ១ | ម³ | 0.17 | | |
| ៨ | ឈើលេខ ៣ | ម³ | 1.40 | | |
| ៩ | ដែកគោល | គក្រ | 3.50 | | |
| ១០ | លួស | គក្រ | 16.00 | | |
| ១១ | ដែកអ៊ីយ ៦០x៦០x៥០ | ម | 14.00 | | |
| ១២ | តម្លៃដឹកជញ្ជូនសំភារៈចូលការដ្ឋាន | តោន | 129.00 | | |
| ១៣ | ដឹកជញ្ជូនសំភារៈចេញពីការដ្ឋាន | តោន | 1.50 | | |
| ១៤ | ពលកម្មគ្មានជំនាញ | នាក់ថ្ងៃ | 225.00 | | |
| ១៥ | ពលកម្មមានជំនាញខ្លះ | នាក់ថ្ងៃ | 95.00 | | |
| ១៦ | ពលកម្មមានជំនាញ | នាក់ថ្ងៃ | 33.00 | | |
| ១៧ | ឧបករណ៍តូចតាច (៣%នៃពលកម្ម) | | | ៣% | |
| សរុបតម្លៃ | | | | | |

យើងខ្ញុំយល់ព្រមនូវ តម្លៃឯកតាខាងលើនឹងប្រើសម្រាប់ការគណនាតម្លៃការងារបន្ថែម ដែលបានណែនាំ និង យល់ព្រមដោយអ្នកគ្រប់គ្រងគម្រោង ។

ហត្ថលេខា និងត្រា

ឈ្មោះ ..........................................................

មុខងារ.........................................................

កាលបរិច្ឆេទ...................................................

ទម្រង់លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ

**ធនាគារ**.............

លេខ..................

# លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ

## សូមគោរពជូន
## លោកមេឃុំ ឈូក

ដោយហេតុថាក្រុមហ៊ុន................មានបំណងដាក់ពាក្យសុំដេញថ្លៃកិច្ចសន្យាជួសជុលទំនប់ស្ទាក់ទឹកតាំងសៀន ប្រវែង២២៥ម៉ែត្រ ទទឹងខ្នងលើ៥ម៉ែត្រ និងសាងសង់លូប្រអប់ទ្វាទឹកឈើ ភ្លោះមុខកាត់២,៥ម៉ែត្រx កំពស់២ម៉ែត្រ ប្រវែង៦ម៉ែត្រ ១កន្លែងរបស់ឃុំឈូក ដែលនឹងត្រូវប្រជុំបើកសំណើដេញថ្លៃនៅថ្ងៃទី....... .ខែ.......ឆ្នាំ២០១៧ តាមសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃសម្រាប់កិច្ចសន្យារបស់ក្រុមប្រឹក្សាឃុំ ឈូក ចុះថ្ងៃទី.. ខែ......ឆ្នាំ២០១៧។

យើងខ្ញុំសូមធានា និងទទួលខុសត្រូវចំពោះលោកមេឃុំ ឈូក នូវប្រាក់កក់ធានាការដេញថ្លៃចំនួន៣៣៥ដុល្លារ (បីរយសាមសិបប្រាំដុល្លារអាមេរិកគត់)។

ក្នុងករណីមានល័ក្ខខ័ណ្ឌណាមួយកើតមានឡើងក្នុងចំណោមល័ក្ខខ័ណ្ឌទាំងបីខាងក្រោម ៖

1. ប្រសិនបើអ្នកដេញថ្លៃដកពាក្យរបស់ខ្លួនក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ។
2. ប្រសិនបើអ្នកដេញថ្លៃមិនព្រមចុះហត្ថលេខាលើកិច្ចសន្យា ក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ។
3. ប្រសិនបើអ្នកដេញថ្លៃមិនព្រមកក់ប្រាក់ធានាការអនុវត្ត។

នោះធនាគារយើងខ្ញុំនឹងធ្វើការផ្ទេរបង្វែរចូលថវិការជូននូវចំនួនប្រាក់ខាងលើ នៅពេលដែលបានទទួលពាក្យស្នើសុំជាលាយល័ក្ខណ៍អក្សរពីលោកមេឃុំ ឈូក។

លិខិតធានានេះមានសុពលភាពរហូតដល់ថ្ងៃទី...........ខែ...........ឆ្នាំ២០១៧។

ធ្វើនៅ........... ថ្ងៃទី....... ខែ............ ឆ្នាំ២០១៧

**នាយកធនាគារ**

ទម្រង់លិខិតធានាប្រាក់កក់ធានាការអនុវត្ត

**ធនាគារ**.............

លេខ..................

# លិខិតធានាប្រាក់កក់ធានាការអនុវត្ត

## សូមគោរពជូន
## លោកមេឃុំ ឈូក

ដោយហេតុថាក្រុមហ៊ុន.................. បានទទួលលិខិតលេខ........... ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ២០១៧ របស់ឃុំឈូក ស្ដីពីការសម្រេចផ្ដល់កិច្ចសន្យា ជួសជុលទំនប់ស្នាក់ទឹកតាំងសៀន ប្រវែង២២៥ម៉ែត្រ ទទឹងខ្នងលើ៥ម៉ែត្រ និងសាងសង់លូប្រអប់ទ្វាទឹកឈើ ភ្លោះមុខកាត់២,៥ម៉ែត្រx កំពស់២ម៉ែត្រ និងប្រវែង៦ម៉ែត្រ ១កន្លែង។ ក្នុងតម្លៃកិច្ចសន្យាចំនួន.......................... (ជាអក្សរ.....................................)។

ក្នុងលិខិតសម្រេចផ្ដល់កិច្ចសន្យា ឃុំបានកំណត់ឱ្យក្រុមហ៊ុនតម្កល់ប្រាក់កក់ធានាការអនុវត្តចំនួន......ដុល្លារ (ជាអក្សរ............) ក្នុងទម្រង់ជាលិខិតធានាប្រាក់កក់ធានាការអនុវត្ត ដែលចេញដោយធនាគារ.......... ដើម្បីធានាការអនុវត្តកាតព្វកិច្ចស្របតាមល័ក្ខខ័ណ្ឌនៃកិច្ចសន្យា។

យើងខ្ញុំសូមធានា និងទទួលខុសត្រូវចំពោះលោកមេឃុំ ........នូវប្រាក់កក់ធានាការអនុវត្តចំនួន.......ដុល្លារ (ជាអក្សរ.............)។

ប្រាក់កក់ខាងលើនេះនឹងផ្ទេរបង្វែរចូលថវិការដ្ឋ នៅពេលមានពាក្យស្នើសុំជាលាយល័ក្ខណ៍អក្សររបស់លោកមេឃុំ ឈូក ដែលបញ្ជាក់ថា អ្នកទទួលការ អ្នកផ្ដល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ទំនិញមិនគោរពតាមល័ក្ខខ័ណ្ឌនៃកិច្ចសន្យា ហើយក្រុមហ៊ុន....................គ្មានសិទ្ធិប្រកែក ឬតវ៉ាឡើយ។

លិខិតធានានេះមានសុពលភាពរហូតដល់ថ្ងៃទី....... ខែ....... ឆ្នាំ........។

ធ្វើនៅ................. ថ្ងៃទី....... ខែ........... ឆ្នាំ.........

**នាយកធនាគារ**